**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ ០០១៥/២៣ ន.គ.ស/ណ.ស.ក.

ថ្ងៃ អង្គារ ៦ រោច ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង

## ស្តីពី

## ការផ្តល់ពេលវេលាបន្ថែមក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២២ សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ មិនរងសវនកម្មឯករាជ្យ មកនិយ័តករគណនេយ្យនិងសវនកម្ម

យោងតាមសេចក្តីជូនដំណឹងលេខ ០០១៣/២៣ ន.គ.ស/ស.ជ.ណ ចុះថ្ងៃទី ៥ ខែមេសា ឆ្នាំ២០២៣ ស្តីពីការរំលឹកអំពីកាតព្វកិច្ចដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២ មកនិយ័តករគណនេយ្យ និងសវនកម្ម តាមប្រព័ន្ធអនឡាញ (E-Filing System) សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ មិនរងសវនកម្មឯករាជ្យ កាលបរិច្ឆេទដាក់បញ្ជូន នឹងត្រូវផុតកំណត់នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៣ ខាងមុខនេះ។ ប៉ុន្តែ ដោយមានការស្នើសុំពេលវេលាបន្ថែមពីម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ **និយ័តករគណនេយ្យនិងសវនកម្ម** នៃ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** សម្រេចផ្តល់ជូនសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ មិនរងសវនកម្មឯករាជ្យ នូវពេលវេលាបន្ថែមចំនួន ***៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទី១៦ ខែមេសា ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣*** ដើម្បីដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគណនេយ្យ២០២២ របស់ខ្លួន មក **ន.គ.ស.** តាមប្រព័ន្ធអនឡាញ (E-Filing for System)។

**ការខកខានមិនបានដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២ មក ន.គ.ស. តាមកាលបរិច្ឆេទកំណត់ខាងលើ ជាកម្មវត្ថុនៃការពិន័យអន្តរការណ៍ ដូចបានកំណត់នៅក្នុងអនុក្រឹត្យលេខ៧៩ អនក្រ.បក. ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម។**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ មិនរងសវនកម្មឯករាជ្យ ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**អគ្គនាយក**

**ប៊ូ ចារិន**

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សូមចូលរួមក្នុង Telegram Channel របស់និយ័តករគណនេយ្យនិងសវនកម្ម

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០២៣ ៨៨២ ១១១
Phone: 023 882 111